24-06-96

35

ព្រះរាជក្រម នស/រកម/០១៩៦/២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧត្តគោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និភរោត្តម

ចម្ក្រីកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅច្បងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ សីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័ត នៅសម័យប្រជុំ
នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ

ច្បាប់

ស្តីពី

ការបង្កើតក្រសួងកិច្ចការនារី

មាត្រា ១ : ត្រូវបានបង្កើតក្រសួងកិច្ចការនារី ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រសួងកិច្ចការនារីមានសមត្ថកិច្ចដឹកនាំ និង គ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : ក្រសួងកិច្ចការនារី ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបជានារី ដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

មាត្រា ៤ : ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមព្រះរាជទានព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១
ឯកឧត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហ៊ុន សែន

ព្រះហស្តលេខា
ឯកឧត្តម សីហនុ

* * *